# We mask date

## និពន្ធដោយៈ ម៉ៅ ចាន់រស្មី

សំឡេងភ្លេងហ្សាសលាន់ចេញពីម៉ាស៊ីនបំពងសំឡេងយ៉ាងពិរោះរណ្ដំ ងំពេញក្នុងហាងកាហ្វេតូចពណ៌លឿងទុំ រៀបចំដោយបង្អួចធំៗ និងជញ្ជាំងបែប ចំណាស់ ជាកន្លែងដែលខ្ញុំធ្វើការ តែអារម្មណ៍បែរជាឯកាចម្លែក ព្រោះតុកៅអី ដែលធ្លាប់តែមានមនុស្សអ៊ូអរ អង្គុយជជែកគ្នាលេង ប្រែជាទទេស្អាត គ្រប់យ៉ាង នៅទីនេះហាក់ស្ងៀមទ្រឹង នឹងថ្កល់ដូចជាពិភពលោកទាំងមូលត្រូវបានបញ្ឈប់ លែងវិលទៅមុខតទៅទៀត។ ហើយក៏មិនដឹងថាពេលណាទើបគ្រប់យ៉ាងត្រលប់ មកដំណើរការដូចធម្មតាវិញដែរ។ ពេលនេះភ្លេងពិរោះយ៉ាងណា ក៏ស្ដាប់លែង ដឹងថាពិរោះ ព្រោះអ្វីដែលខ្ញុំស្ដាប់ឮ គឺមានតែសំឡេងងឹតង៉តៗ ចេញពីប្រដាប់ ជូតសម្អាតតុដែលខ្ញុំកំពុងរុញទៅរុញមកទាំងភាពធុញទ្រាន់តែប៉ុណ្ណោះ។

"តើយើងអាចស្រឡាញ់មនុស្សម្នាក់ ដោយមិនធ្លាប់ឃើញមុខគេសោះដែរទេ?" បញ្ញា មិត្តរួមការងាររបស់ខ្ញុំសួរឡើង ដូចជាកាត់ចង្វាក់ការបណ្ដែតអារម្មណ៍ដែលកំពុងហោះហើរទៅឆ្ងាយរបស់ខ្ញុំឱ្យត្រលប់មកវិញ។

"អត់អីសួរមែនទេ?" ខ្ញុំជូតតុក្នុងហាងកាហ្វេបណ្ដើរ តបទៅវិញទាំងមុខ ស្មើថៃស។

បញ្ញាញោចស្មាបន្តិច "អត់អីសួរមែនហ្នឹង! ម៉ែ្ងៗអង្គុយមើលតែមុខគ្នា ទៅវិញទៅមក ចង់ស្រេ្កសស្លាប់ទៅហើយ!" បញ្ញានិយាយទាំងផ្អែកខ្នងនឹងកៅអី ងើយមើលពិដានមុននឹងសួរបន្ត "ចុះឯងគិតថាអាចទេ?"

"មិនអាចទេ!" ខ្ញុំតបខ្លីៗ រួចក៏ងាកមកជូតតុបន្តទៀត។ និយាយមិនទាន់ ផុតពីមាត់ស្រួលបួលផង ស្រមោលអ្វីម្យ៉ាងក៏រត់កាត់មុខដូចជាព្យុះសង្ឃរា ហើយ ក៏ដួលរមួលបី

ប្អូនត្រលប់នៅចំពោះមុខខ្ញុំ បុកតុ បុកកៅអីពេញហាង។ មួយសន្ទុះ ទើបខួរក្បាលចាប់ផ្តើមដំណើរការឡើងវិញ ទើបដឹងថារបស់មិញនេះ គឺជា មនុស្ស!

នារីមាឌតូច សក់រួញ ពាក់វ៉ែនតាម្ទូបស៊ុមមូល ថែមទាំងពាក់ម៉ាសការពារ ជិតមុខ ទើបខ្ញុំអាចមើលឃើញត្រឹមតែកែវភ្នែកតូចៗរបស់នាង នៅពីក្រោម កញ្ចក់សថ្លាតែប៉ុណ្ណោះ។

ស្រីតូចប្រញាប់ងើបឈរឡើងយ៉ាងរហ័ស ដូចជាគ្មានរឿងអ្វីកើតឡើង សោះអ៊ីចឹង។ ការពិតនាងរអិលដួលនឹងទឹកដែលខ្ញុំកំពុងជូតឥដ្ឋហ្នឹងឯង។

"សុំទោស!" ខ្ញុំនិយាយទាំងខិតទៅជិតនាង ក្រែងនាងត្រូវការជំនួយ តែ នាងបែរជាស្ទុះថយចេញយ៉ាងឆ្ងាយ ចម្ងាយប្រហែលមួយម៉ែត្រ ទើបលើក ក្រដាសណូតមួយឡើង ដែលខ្ញុំប្រឹងអានទំរាំតែដាច់ថា៖

*"អាល់ម៉ុនឡាតេ ស្ករតិច កាហ្វេច្រើន ទឹកកកល្មម"*

ដឹងថាខ្ញុំអានចប់ហើយ ស្រីតូចក៏ដាក់ដបអ៊ីណុកមួយ ចុះនៅលើតុក្បែរ ដៃ។ វាជាដបទឹកដែលស្រោបពីឈើត្នោត ព្រមទាំងមានឆ្លាក់ឈ្មោះនៅលើ នោះថា "ទេព្តី" ដែលវាប្រហែលជាឈ្មោះរបស់នាង។

"បាទ!" ខ្ញុំងក់ក្បាលតបវិញ ទាំងនៅញញឹមអស់សំណើចនឹងកាយវិការ ប្លែកៗរបស់នាងនៅឡើយ រួចស្រវាដបនោះ ដើរទៅឆុងកាហ្វេតាមការកម្ម៉ង់ ដែលនាងរៀបរាប់គ្រប់យ៉ាង មុននឹងហុចដបអ៊ីណុកដាក់កាហ្វេនោះត្រលប់ ទៅនាងវិញ ជាមួយណូតមួយឃ្លាដែលខ្ញុំសរសេរនៅលើដបទឹកនោះថា៖

*"សង្ឃឹមថាចង្កេះមិនអីទៅចុះ! រីករាយថ្ងៃចុងសប្តាហ៍! :) "*

គ្រាន់តែបានដបដល់ដៃ នាងហុចលុយមក រួចក៏រត់រឹងសឹងតែបុកទ្វារ! មកក៏រត់ ទៅវិញក៏រត់ រហូតខ្ញុំក៏មិនយល់ដែរថា នាងប្រញាប់ទៅណាទៅ?

នាងត្រឹមតែជាភ្ញៀវដំបូងនៅក្នុងថ្ងៃនេះទេ តែក៏ជាមនុស្សដំបូងដែលធ្វើឱ្យ ខ្ញុំញញឹមបាន ក្នុងរយៈពេលប៉ុន្មានខែកន្លងមក! តែ... ខ្ញុំអាចចួបនាងទៀត ដែរទេ?

គិតដល់ចំនុចនេះ ខ្ញុំស្រាប់តែមានអារម្មណ៍ប្លែក! ប្លែកត្រង់ថា ខ្ញុំបែរជាបន់ សុំឱ្យស្អែកឆាប់មកដល់ ក្រែងលោអាចចួបនាងម្តងទៀត!

ព្រឹកនេះខ្ញុំភ្ញាក់តាំងពីព្រលឹម ជាមួយនឹងក្តីសង្ឃឹម ទោះបីជាមិនប្រាកដចិត្ត ថាស្នាដៃឆុងកាហ្វេរបស់ខ្ញុំត្រូវចិត្តនាងឬអត់ក៏ដោយ!

កំពុងតែអង្គុយគិតវែងឆ្ងាយ ដបឡោតក៏ត្រូវបានដាក់ចុះនៅក្បែរដៃខ្ញុំព្រម ជាមួយក្រដាសណូតពណ៌លឿងដែលបិទនៅលើនោះ សរសេរថា៖

"សុំកាហ្វេដូចពីម្សិលមិញ! ហើយក៏អរគុណ! ចង្កេះមិនទាន់បាក់ទេ នៅរស់ដូចធម្មតា!"

មិនទាន់ងើយមើលមុខម្ចាស់ដប ក៏ដឹងទៅហើយថា ជានរណាគេ! ឃើញ ណូតនេះភ្លាម ខ្ញុំក៏ញញឹមបិទមាត់មិនជិត ត្បិតក្តីសង្ឃឹមពិតជាបានសម្រេចមែន! តែខ្ញុំមិនដឹងថាគួរឆ្លើយតបបែបណាទើបល្អទេ ព្រោះនាងឈរមួយម៉ែត្រពីខ្ញុំ ឯណោះ។ ចុងក្រោយខ្ញុំក៏សរសេរលើណូតថ្មីត្រលប់ទៅនាងវិញថា៖

"កាហ្វេនេះហ្វ្រី! ដើម្បីសងការឈឺចាប់ពីម្សិលមិញ!"

ឃើញសារនេះរួច ខ្ញុំដឹងថានាងញញឹម ព្រោះកែវភ្នែកមូលៗរបស់នាង ប្រែជារាងស្រៈ " ិ" យ៉ាងច្បាស់ក្រឡែត។

"អរគុណ!" និយាយរួច នាងក៏រត់រឹងចេញពីក្នុងហាង ធ្វើឱ្យខ្ញុំញញឹមតាម រាប់ម៉ោងមិនទាន់ឈប់។ គ្រាន់តែប៉ុណ្ណឹងសោះ អាចធ្វើឱ្យខ្ញុំសប្បាយចិត្ត ដល់ម្ល៉ឹង?

ភ្លាមនោះ សំនួររបស់បញ្ញាក៏ផុសឡើងក្នុងខួរក្បាលរបស់ខ្ញុំម្តងទៀត...

*"តើយើងអាចស្រឡាញ់មនុស្សម្នាក់ ដោយមិនធ្លាប់ឃើញមុខគេសោះ ដែរទេ?"*

ខ្ញុំចាប់ផ្ដើមរារែកនឹងចម្លើយដែលខ្ញុំបានឆ្លើយកាលពីម្សិលមិញ ព្រោះការពិត… យើងប្រហែលជាអាចស្រឡាញ់មនុស្សម្នាក់បាន ដោយមិនធ្លាប់ ឃើញមុខគេឡើយ ហើយនេះប្រហែលជាចំនុចចាប់ផ្ដើមនៃក្ដីស្រលាញ់មួយ នោះ ព្រោះក្នុងមួយប៉ព្រិចភ្នែក វត្តមានស្រីតូចម្នាក់ដែលខ្ញុំមិនធ្លាប់ឃើញមុខ ក្លាយជាពន្លឺដ៏ស្រស់ស្អាតក្នុងជីវិតដ៏អាប់អួររបស់ខ្ញុំ។ នាងក្លាយជាមូលហេតុ ដែលខ្ញុំចង់ងើបពីព្រឹកមកធ្វើការនៅហាងកាហ្វេ។ ជាមូលហេតុដែលធ្វើឱ្យខ្ញុំ ស្ដាប់ភ្លេងហ្សាសក្នុងហាងពិរោះជាងមុន។ ជាមូលហេតុដែលធ្វើឱ្យខ្ញុំញញឹមបាន រាល់ពេលដែលអានណូតនៅលើដបទឹករបស់នាង។

ថ្ងៃច័ន្ទនេះភ្លៀងធ្លាក់យ៉ាងរណ្ដំ ជញ្ជ្រំតាំងពីព្រឹករហូតដល់ល្ងាច។ ហាង កាហ្វេក៏ស្ងាត់ជ្រាបមានតែខ្ញុំពីរនាក់បញ្ញាតែប៉ុណ្ណោះ។ ខ្ញុំបានត្រឹមតែសម្លឹង មើលទៅមាត់ទ្វារហាង ទាំងអន្ទះសារនៅក្នុងចិត្ត ត្បិតមួយថ្ងៃនេះមិនឃើញ ស្រីតូចទេព្ដីមកទីនេះដើម្បីខ្ចប់កាហ្វេដូចជារាល់ដងទេ។ វិនាទីនេះធ្វើឱ្យខ្ញុំ ភ្ញាក់ថា ការពិតខ្ញុំមិនមែនចង់ត្រឹមតែអានណូតលើដបទឹករបស់នាងទេ ប៉ុន្តែខ្ញុំ ចង់ជួបនាង! ហើយមិនមែនជួបក្នុងនាមជាអ្នកឆុងកាហ្វេ និងអ្នកទិញកាហ្វេ នោះដែរ! តែជាការជួបដែលជ្រាលជ្រៅជាងនោះ! គួរឱ្យស្ដាយដែលខ្ញុំមិនបាន សួរនាងឱ្យច្បាស់! ថានាងជានរណា? ធ្វើការនៅឯណា? ហើយដែលសំខាន់ មានសង្សារហើយឬនៅ?

ឱកាសមិនចេះតែមានច្រើនដងទេក្នុងមួយជីវិត ដូច្នេះបើវាសនាចារឱ្យ ខ្ញុំបានជួបនាងម្ដងទៀតមែន ខ្ញុំត្រូវតែសុំនាងណាត់ជាផ្លូវការណ៍! បើខ្ញុំមិនក្ដោប ឱកាសនៅពេលនេះ តើពេលណា? បើរង់ចាំដល់ពេលដែលសភាពការណ៍ ត្រលប់ទៅប្រក្រតី តើខ្ញុំត្រូវរង់ចាំប៉ុន្មានឆ្នាំទៀតទៅ? បើខ្ញុំមិនរៀនរស់នៅក្នុង ថ្ងៃនេះឱ្យបានល្អ វាប្រហែលជាគ្មានថ្ងៃដែលល្អនោះទេ!

"ត្រូវហើយ!" ខ្ញុំស្រែកខ្លាំងៗតែម្នាក់ឯង ធ្វើឱ្យបញ្ញាដែលឈរក្បែរនេះ ភ្ញាក់ក្រញាង។

"ត្រូវស្អី?" បញ្ញាសួរទាំងមុខឆ្ងល់។

"គ្មានស្អីទេ!" ខ្ញុំតបរួចក៏ប្រញាប់ដើរចេញពីបញ្ញាយ៉ាងលឿន។

ព្រឹកថ្ងៃអង្គារឈានចូលមកដល់។ ហើយវត្តមានស្រីតូចម្ចាស់ដបខ្មៅតក៏ ផុសឡើងក្នុងហាងកាហ្វេម្ដងទៀតដូចការរំពឹងទុក។ តែលើកនេះ វាខុសពីរាល់ ដង ពេលដែលកែវភ្នែកយើងទាំងពីរនាក់ប្រសព្វគ្នា កណ្ដាលទីធ្លាហាងកាហ្វេ ដ៏ស្ងប់ស្ងាត់ វាធ្វើឱ្យខ្ញុំអាចស្ដាប់ឮសំឡេងបេះដូងខ្លួនឯងដែលកំពុងលោតញាប់ តន្ត្រីន លប់បាត់សំឡេងភ្លេងហ្វ្រាសដែលយើងចាក់នៅក្នុងហាងអស់រលីង។ មិនរង់ចាំដល់ពេលដែលនាងហុចដបទឹកមកទៀតទេ ខ្ញុំលើកក្រដាសណ្ឌួត ដែលខ្ញុំសរសេរទុករួចនោះឡើងយ៉ាងខ្ពស់ ទាំងបេះដូងលោតញាប់ស្ទើរតែបុក ធ្លាយចេញពីទ្រូងទៅហើយ ស្របពេលដែលរង់ចាំចម្លើយ ថានាងនឹងឆ្លើយយ៉ាង ណា ចំពោះសំនួរដែលខ្ញុំបានសរសេរលើនោះថា៖

“If you are single, would you go on a mask date with me?”

ខ្ញុំឈររង់ចាំចម្លើយទាំងគាំងដូចជារូបចម្លាក់ តែមើលទៅនាងហាក់ដូចជា ភាំងជាងខ្ញុំទៅទៀត ព្រោះពេលនេះ បន្តិចក៏នាងមិនកម្រើកដែរ។ តែវាមិនដូចជា ការគិតទុកសោះ នាងមិនត្រឹមតែមិនឆ្លើយទេ ថែមទាំងរត់ចេញរឹង ហើយក៏បាត់ ស្រមោលឈឹងតែម្ដង។ ខ្ញុំក៏ឈរសម្លឹងមើលទៅមាត់ទ្វារ ទាំងអស់សង្ឃឹម តែក៏ ប្រឹងញញឹមលើកទឹកចិត្តខ្លួនឯងទៅថា គ្មានអ្នកណាឆ្កួតដូចខ្ញុំ សុំណាត់ជួបគ្នា កំឡុងពេលកូវីដយ៉ាងនេះទេ! នាងមិនព្រម គឺត្រឹមត្រូវហើយ! ណ្ហើយចុះ... យ៉ាងហោចណាស់ខ្ញុំបានសាកល្បងរួចហើយ! ចម្លើយយ៉ាងម៉េចនោះមិន សំខាន់ទេ! ជួនកាលវាអាចជានាងមានសង្សាររួចទៅហើយ! ឬមួយនាងអាចមិន ចាប់អារម្មណ៍នឹងខ្ញុំក៏ថាបានដែរ!

មួយសន្ទុះស្រាប់តែទ្វារហាងត្រូវបានបើកឡើងម្ដងទៀត ជាមួយរាងកាយ តូចស្ដើង របស់នារីសក់រួញ ពាក់វ៉ែនតាម្ប៉ូបដែលទើបតែរត់ចេញទៅមុននេះបន្តិច ធ្វើឱ្យខ្ញុំភាំងបើកភ្នែកក្រឡង់។

នាងភ្លេចអីមែនទេ?

បម្រុងហារមាត់សួរ តែរបស់ម្យ៉ាងធ្វើឱ្យខ្ញុំបិទមាត់ទៅវិញយ៉ាងរហ័ស ព្រោះតែត្រូវប្រើភ្នែកអានពាក្យមួយម៉ាត់ ដែលនាងសរសេរលើណ្ឌួតតូចមួយ ខ្លាចថាបើអានវាខុសច្បាស់ជាវីវរមិនខាន ប៉ុន្តែខ្ញុំអានច្រើនដងហើយ ចម្លើយ គឺដដែល៖

“YES”

នាងយល់ព្រមណាត់ជួបទាំងពាក់ម៉ាសជាមួយខ្ញុំហើយ!!

ពេលនេះពួកយើងឈរទល់មុខគ្នាក្នុងរយៈចម្ងាយប្រហែលមួយម៉ែត្រ ដោយមិននិយាយអ្វីទាំងអស់ ទុកឱ្យចម្រៀងហ្សាសរបស់លោកតា ស៊ីន ស៊ីសាមុត ក្នុងហាងកាហ្វេបរិយាយរ៉ាយរ៉ាប់ពីអារម្មណ៍ទាំងប៉ុន្មានជំនួសយើង ទៅចុះ ព្រោះវាគ្រប់គ្រាន់ដើម្បីបង្ហាញថា ខ្ញុំរំភើបចិត្តយ៉ាងណានៅពេលនេះ។

**ចប់**

Asian Literature Project "YOMU" ©Japan Foundation